# ព្រះរាជក្រឹត្យ

នស/រកត/១០២០/១០៧៣

## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃ
## ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលសរសេរជាអក្សរកាត់ថា **ក.ជ.វ.ប.ន.** ដើម្បីជំរុញកិច្ចអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែមានការរីកចម្រើន។

## ជំពូកទី២
## សមាសភាពរបស់ គ.ជ.វ.ប.ន.

**មាត្រា២ .-**

**គ.ជ.វ.ប.ន.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងផែនការ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងសុខាភិបាល | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប | សមាជិក |
| - រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល១រូប | សមាជិក |
| - អគ្គលេខាធិការរងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា១រូប | សមាជិក |
| - អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ១រូប | សមាជិក |
| - តំណាងស្ថាប័នសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មួយចំនួន | សមាជិក |
| - តំណាងសភាពាណិជ្ជកម្មកម្ពុជា១រូប | សមាជិក |
| - អគ្គនាយកនៃវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិកអចិន្ត្រៃយ៍។ |

សមាសភាពជាក់ស្តែងនៃ **គ.ជ.វ.ប.ន.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ ក.ជ.វ.ប.ន.

**មាត្រា៣ .-**

**ក.ជ.វ.ប.ន.** មានតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលលើការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងមានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ សម្រេច និងជំរុញអនុវត្តន៍គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- សម្របសម្រួលដឹកនាំការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងក្របខណ្ឌអន្តរក្រសួង ស្ថាប័ន
- កំណត់តម្រូវការអាទិភាពនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលស្នើឡើងដោយក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ និងអង្គភាពឯកជនដែលពាក់ព័ន្ធ
- ពិនិត្យនិងសម្រេចលើសំណើដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលរៀបចំដោយលេខាធិការដ្ឋាន **ក.ជ.វ.ប.ន.**
- កៀរគរជំនួយនិងការគាំទ្រធនធានហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្ស ដែលជាតម្រូវការនៃស្ថាប័ន ឬអង្គភាពដែលពាក់ព័ន្ធនឹងការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ពិនិត្យនិងសម្រេចឱ្យធ្វើការផ្សព្វផ្សាយលើការយល់ដឹងនិងចែករំលែកផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ពិនិត្យនិងសម្រេចលើការវាយតម្លៃផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ជំរុញនិងលើកទឹកចិត្ត ការចូលរួម ការលើកស្ទួយក្នុងកិច្ចអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ពីគ្រប់មជ្ឈដ្ឋាន
- កំណត់គោលការណ៍អភិវឌ្ឍធនធានមនុស្ស ដើម្បីបម្រើតម្រូវការនិងការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងគម្រោងកម្មវិធីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ហើយធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ ក.ជ.វ.ប.ន.

**មាត្រា៤ .-**

**ក.ជ.វ.ប.ន.** ត្រូវធ្វើការប្រជុំយ៉ាងតិច២(ពីរ)ដងក្នុង១(មួយ)ឆ្នាំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ប្រធាន **ក.ជ.វ.ប.ន.** អាចកោះប្រជុំជាវិសាមញ្ញបាន។

ក្នុងពេលដែលប្រធាន **ក.ជ.វ.ប.ន.** អវត្តមានឬមានករណីចាំបាច់ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានទី១ ដើម្បីដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិពីប្រធាន។

របៀបរបបការងារនិងកិច្ចដំណើរការប្រជុំរបស់ **ក.ជ.វ.ប.ន.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**មាត្រា៥ .-**

ប្រធាន **ក.ជ.វ.ប.ន.** មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ ឬតំណាងនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ឬឥស្សរជនដែលមានបទពិសោធន៍ សមត្ថភាព និងជំនាញវិជ្ជាជីវៈ ចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ **ក.ជ.វ.ប.ន.** តាមការចាំបាច់។

**មាត្រា៦ .-**

**ក.ជ.វ.ប.ន.** អាចមានទីប្រឹក្សានិងជំនួយការ ដែលជាអ្នកបច្ចេកទេសនិងជំនាញផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ទាំងជាតិនិងអន្តរជាតិតាមការចាំបាច់។

**មាត្រា៧ .-**

**ក.ជ.វ.ប.ន.** មានគណៈប្រឹក្សាយោបល់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលប្រមូលផ្តុំដោយឥស្សរជន បញ្ញវន្ត និងអ្នកជំនាញផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គ្រប់មជ្ឈដ្ឋាន ដើម្បីជួយការងារឬផ្តល់យោបល់ជូន **ក.ជ.វ.ប.ន.**។

តួនាទីនិងភារកិច្ចរបស់គណៈប្រឹក្សាយោបល់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ជ.វ.ប.ន.**។

**មាត្រា៨ .-**

**ក.ជ.វ.ប.ន.** មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាលេខាធិការដ្ឋាន។ អគ្គនាយកនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាប្រធានលេខាធិការដ្ឋាន។

ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន **ក.ជ.វ.ប.ន.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ជ.វ.ប.ន.**។

លេខាធិការដ្ឋាន **ក.ជ.វ.ប.ន.** មានសិទ្ធិប្រើមន្ត្រីនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងការបំពេញភារកិច្ច។

**មាត្រា៩ .-**

**ក.ជ.វ.ប.ន.** មានសិទ្ធិប្រើរូបសញ្ញានិងត្រាដោយឡែករបស់ខ្លួនដែលកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥

## ថវិកាសច្ច

**មាត្រា១០ .-**

ការចំណាយសម្រាប់ដំណើរការរបស់ **ក.ជ.វ.ប.ន.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ក.ជ.វ.ប.ន.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់នូវមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀតតាមវិធីច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៤/១១៣៦ ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ សៅរ៍ ៩រោច ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២០

**ក្នុងព្រះបរមនាមនិងតាមព្រះរាជឱង្ការបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

នស/រកត.១០២០-១០៩៥

**សម្តេចវិបុលសេនាភក្ដី សាយ ឈុំ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

កិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**